**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ** :.........០០៥/២០.................**ក.ប**/ស.ជ.លា.ខ.ល

# សេចក្តីជូនដំណឹង
## ស្តីពី
## ការតម្រូវឱ្យធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទទំនាក់ទំនងរបស់កម្មករនិយោជិត

ដើម្បីធានាដល់ការផ្តល់ព័ត៌មានចាំបាច់នានាជូនបងប្អូនកម្មករនិយោជិត ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំ និងកំណត់ដល់ភាគីពាក់ព័ន្ធដូចខាងក្រោម៖

**១. ចំពោះបងប្អូនកម្មករនិយោជិត៖**

- ត្រូវផ្តល់លេខទូរស័ព្ទដែលអាចទំនាក់ទំនងបានចំនួន ១ខ្សែ ទៅអ្នកទទួលបន្ទុករដ្ឋបាល ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសណ្ឋាគារ ដែលខ្លួនកំពុងធ្វើការ ដោយសរសេរឱ្យបានច្បាស់ៗ និងត្រឹមត្រូវដើម្បីឱ្យអ្នកទទួលបន្ទុករដ្ឋបាលធ្វើបច្ចុប្បន្នភាពតារាងបញ្ជីឈ្មោះ និងប្រគល់ឱ្យអធិការការងារមុនថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០នេះ។
- ត្រូវរក្សាលេខទូរស័ព្ទ ដែលបានផ្តល់ឱ្យអ្នកទទួលបន្ទុករដ្ឋបាលនេះជាដាច់ខាតក្នុងអំឡុងខែមីនា មេសា និងឧសភា ឆ្នាំ២០២០នេះ។ ក្រោយខែឧសភា ឆ្នាំ២០២០ ប្រសិនជាមានការផ្លាស់ប្តូរលេខទូរស័ព្ទត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់អ្នកទទួលបន្ទុករដ្ឋបាលជាបន្ទាន់។
- សាមីជនត្រូវទទួលខុសត្រូវខ្លួនឯងក្នុងការខាតបង់ផលប្រយោជន៍ផ្សេងៗ ដែលបណ្តាលមកពីការខកខានផ្តល់លេខទូរស័ព្ទជូនទៅដល់ អ្នករដ្ឋបាល មុនថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០នេះ។

**២. ចំពោះម្ចាស់ ឬនាយក ឬប្រធានរដ្ឋបាល របស់ក្រុមហ៊ុន រោងចក្រ សហគ្រាស និងសណ្ឋាគារ**

- ត្រូវចាត់ឱ្យអ្នកទទួលបន្ទុករដ្ឋបាល និងគណនេយ្យរបស់ខ្លួនធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទទំនាក់ទំនងរបស់កម្មករនិយោជិត នៅក្នុងក្រុមហ៊ុន រោងចក្រ សហគ្រាស និងសណ្ឋាគាររបស់ខ្លួន។
- ត្រូវធ្វើបញ្ជីឈ្មោះកម្មករនិយោជិត ដោយឈរលើទម្រង់ឯកសារស្វ័យប្រកាសប្រចាំខែរបស់ ប.ស.ស. ដោយបន្ថែមកូឡោនលេខទូរស័ព្ទរបស់កម្មករនិយោជិតម្នាក់ៗ តាមគំរូដូចមានជូនភ្ជាប់ជាមួយ។
- ត្រូវធ្វើបញ្ជីឈ្មោះនេះជា Excel File មក Email: info@nea.gov.kh និងត្រូវធ្វើច្បាប់ដើម ដែលមានវាយត្រានៅគ្រប់ទំព័រ មកនាយកដ្ឋានអធិការកិច្ចការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត សម្រាប់សហគ្រាសដែលស្ថិតនៅក្នុងដែនរាជធានី ខេត្ត ចាប់ពីថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២០ ជាកំហិត។
- ម្ចាស់ ឬនាយកក្រុមហ៊ុន រោងចក្រ សហគ្រាស និងសណ្ឋាគារទាំងឡាយណាដែលខកខានក្នុងការចាត់ចែងការធ្វើបច្ចុប្បន្នភាពលេខទូរស័ព្ទទំនាក់ទំនងរបស់កម្មករនិយោជិត ត្រូវទទួលការពិន័យទៅតាមច្បាប់ស្តីពីការងារ ដោយអធិការការងារ និងត្រូវទទួលទោសទណ្ឌផ្សេងទៀតតាមច្បាប់ជាធរមាន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម ម្ចាស់ ឬនាយក ឬប្រធានរដ្ឋបាលក្រុមហ៊ុន រោងចក្រ សហគ្រាស និងសណ្ឋាគារ បងប្អូនកម្មករនិយោជិត ត្រូវចូលរួមអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះប្រកបដោយប្រសិទ្ធភាព។

ថ្ងៃ ចន្ទ ១៥កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**អ៊ិត សំហេង**

ឧបសម្ព័ន្ធនៃសេចក្តីជូនដំណឹងលេខៈ ០០៩/២០ ក.ប/ស.ជ.ណា.ខ.ល ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ ២០២០

# បញ្ជីឈ្មោះកម្មករនិយោជិត

## សហគ្រាស-គ្រឹះស្ថាន..............................................................................................

## ដែលស្ថិតនៅក្នុងបញ្ជីប្រាក់ខែនៅក្នុងខែ........................ឆ្នាំ២០២០

*លេខអត្តសញ្ញាណសហគ្រាស-គ្រឹះស្ថានរបស់ ប.ស.ស៖..........................*

| ល.រ | អត្ត.ប.ស.ស | ឈ្មោះ | ភេទ | ថ្ងៃខែឆ្នាំកំណើត | សញ្ជាតិ | លេខទូរស័ព្ទ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |

បានបញ្ចប់ត្រឹមលេខរៀងទី ....

ថ្ងៃទី ............ ខែ ........ ឆ្នាំ ...............

ហត្ថលេខា និងត្រា

នាយកក្រុមហ៊ុន

សម្គាល់៖

-សហគ្រាស-គ្រឹះស្ថានត្រូវវាយត្រានៅគ្រប់ទំព័រលើបញ្ជីឈ្មោះនេះ

-សហគ្រាស-គ្រឹះស្ថានត្រូវស្កេន និងផ្ញើបញ្ជីឈ្មោះដែលវាយត្រា និង Excel File មក Email: info@nea.gov.kh